**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខ: ............✓............

ថ្ងៃពុធ១កើតខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ២០១៩

# សេចក្តីប្រកាសព័ត៌មាន

នាថ្ងៃពុធ០១កើតខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី ០៦ ខែមីនា ឆ្នាំ២០១៩ សារព័ត៌មានភ្នំពេញប៉ុស្តិ៍ ត្រង់ទំព័រទី ៨ (ព័ត៌មានជាតិ) បានធ្វើការផ្សព្វផ្សាយព័ត៌មានស្តីពី *"ជនជាតិដើមចង់ឲ្យអាជ្ញាធរពន្លឿនការវាស់ដីនៅភ្នំដោះក្រមុំ"* បានស្រង់មតិលោក គ្រើង តុលា លេខាធិការនៃគណៈកម្មាធិការមជ្ឈមណ្ឌលវប្បធម៌ជនជាតិដើមភាគតិចភ្នំដោះក្រមុំកាលពីថ្ងៃទី ០៥ ខែមីនាឆ្នាំ២០១៩ ថា "ក្នុងកិច្ចប្រជុំដែលដឹកនាំដោយអភិបាលខេត្តលោក ស្វាយ សំអ៊ាង នោះបានសម្រេចកំណត់វិធីសាស្ត្រដោះស្រាយបញ្ហាដីធ្លីលើភ្នំដោះក្រមុំដោយយកកំណត់ហេតុកាលពីឆ្នាំ២០១៦ ធ្វើជាគោលក្នុងការកំណត់ព្រំដីឲ្យបានជាក់លាក់ និងការរក្សាទុកដីសម្រាប់កម្មសិទ្ធិរបស់មន្ទីរចំនួន ៣ ឲ្យនៅដដែលដូចជា *មន្ទីររ៉ែ និងថាមពល* មន្ទីរឧស្សាហកម្ម និងសិប្បកម្ម និងមន្ទីរមុខងារសាធារណៈ" ។

ក្រសួងរ៉ែនិងថាមពល សូមបំភ្លឺជូនអ្នកសារព័ត៌មាននិងសាធារណជន ឱ្យបានជ្រាបថា ក្រោយពីទទួលបានដីកាលេខ ០១៤ ដក/មគរ ចុះថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ២០១៥ របស់រដ្ឋបាលខេត្តមណ្ឌលគិរីស្តីពីការផ្តល់ទីតាំងដីមួយកន្លែងទំហំ ៥,០៧ ហិចតាក្បែរភ្នំដោះក្រមុំសម្រាប់សាងសង់គ្រឹះស្ថានមជ្ឈមណ្ឌលសិក្សាស្រាវជ្រាវរ៉ែ ថាមពល និងប្រេងកាតរួចមក ក្រសួងរ៉ែ និងថាមពលបានធ្វើលិខិតមួយលេខ ១៥៦១ រថ.អកទទ.លស ចុះថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០១៦ ដែលមានកម្មវត្ថុ *"សំណើសុំប្រគល់ទីតាំងដីនៅតំបន់ភូមិដោះក្រមុំ សង្កាត់សុខដុម ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរីជូនរដ្ឋវិញ"* ដែលក្នុងខ្លឹមសារលិខិតបានថ្លែងអំណរគុណ ឯកឧត្តមអភិបាលខេត្ត ចំពោះកិច្ចសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍន៍ធនធានរ៉ែរបស់ជាតិ និងបានបញ្ជាក់ជូនថាក្រសួងបានសម្រេចធ្វើការសាងសង់មជ្ឈមណ្ឌលខាងលើនេះនៅជិតរាជធានីភ្នំពេញ ដូច្នេះក្រសួងសូមប្រគល់ជូនទីតាំងដីខាងលើនេះជូនរដ្ឋបាលខេត្តវិញ ( ដូចមានលិខិតភ្ជាប់ជូន)។ ដូច្នេះក្រសួងរ៉ែ និងថាមពល ក៏ដូចជាមន្ទីររ៉ែនិងថាមពល ខេត្តមណ្ឌលគិរី មិនមានកម្មសិទ្ធិចុះក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋចំពោះដីទំហំ ៥,០៧ ហិចតាក្បែរភ្នំដោះក្រមុំ ដូចដែលលោក គ្រើង តុលា បានលើកឡើងនោះឡើយ ។

អាស្រ័យហេតុនេះ សូមសាធារណជន អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ មេត្តាជ្រាបជាព័ត៌មាន។

**ព័ត៌មានបន្ថែមទាក់ទង៖**
អ្នកនាំពាក្យក្រសួងរ៉ែនិងថាមពល
Email: spokeman@mme.gov.kh